ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៣០៤

ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០២

សាលដីកា

លេខ : ៣៣៦

ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦

# នាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦

ដោយមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឃឹម ប៉ុណ្ណ** | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២- លោក | រៀល មួន | ជាចៅក្រម |
| ៣- លោក | យស់ សូខឿន | ជាចៅក្រម |
| ៤- លោក | យូរ ឧត្តរា | ជាចៅក្រមរបាយការណ៍ |
| ៥- លោកស្រី | គិម សត្ថាវី | ជាចៅក្រម |

ក្រឡាបញ្ជី

លោក **ស៊ិន ភារៈ**

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៥៧ "ច" ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១០៧ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ រវាង :

-ដើមចោទឈ្មោះ **ឈុយ សុរោច** "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅសព្វថ្ងៃនៅភូមិឈើទាលភ្លោះ ឃុំកញ្ជោរ ស្រុកឆ្លូង ខេត្តក្រចេះ ។ ឪពុកឈ្មោះ ឈុយ អ៊ុម "ស" ម្តាយឈ្មោះឡាំង លីវ "ស" ប្រព័ន្ធឈ្មោះហ៊ាន សាភិន "ស" ។

-មានមេធាវីលោក **សួស សាមឿន**

-ចុងចម្លើយឈ្មោះ **លាវ សារិន** (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៩ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅសព្វថ្ងៃនៅភូមិកោះកណ្តុរ ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ ។ ឪពុកឈ្មោះ លាវ យាន "ស" ម្តាយឈ្មោះ ហ៊ាន សាភិន "ស" ប្តីឈ្មោះ ស៊ឹម សារិន ។

<u>**កម្មវត្ថុ**</u> : ប្តឹងទាមទារដីធ្វើជាកម្មសិទ្ធិ ។

-បានឃើញបណ្តឹងសាទុក្ខលេខ២៣៣ ចុះថ្ងៃទី២១-០៦-២០០២ របស់ឈ្មោះ ឈុយ សុភេច ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ៩៧ "ច" ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣០៤ ចុះថ្ងៃទី៣០-៩-២០០២ របស់តុលាការកំពូល ។

-តាមពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០០ របស់ដើមចោទឈ្មោះឈុយ សុភេច ដែលបានប្តឹងសុំសិទ្ធិគ្រប់គ្រងដីធ្វើជាកម្មសិទ្ធិ ដោយមូលហេតុចុងចំលើយបានមកយកដីរបស់ខ្លួនធ្វើជាកម្មសិទ្ធិ។

-តាមពាក្យបណ្តឹង ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០០ របស់ចុងចម្លើយឈ្មោះលាវ សារីន ប្តឹងសុំអោយចែងចែកដីស្រែនេះ(ដីវិវាទ)ជាប្រាំចំណែក ដោយមូលហេតុឪពុកចុងរបស់ខ្លួនបានយកដីកេរ្តិ៍មរតករបស់ឪពុកខ្លួនទៅធ្វើជាកម្មសិទ្ធិ ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៦៩ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការខេត្តក្រចេះ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០០ របស់ដើមចោទទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ប្រគល់ដីស្រែដែលមានទំហំ២៦.២ម ×៦២.៨ម និងដីស្រែដែលមានទំហំ២៦.៥ម គុណ២៦.២ម ដូចក្នុងកំណត់ហេតុវាស់វែងរបស់តុលាការខេត្តក្រចេះ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០០ ស្ថិតនៅភូមិឈើទាលភ្លោះក្រោម ឃុំកញ្ជរ ស្រុកឆ្លូង ខេត្តក្រចេះ ឱ្យទៅដើមចោទឈ្មោះឈុយ សុភេច គ្រប់គ្រងតាមច្បាប់តទៅ ។

៣-បង្គាប់អោយចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី គឺពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តី១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល ប្រាក់ស៊ើបអង្កេត៥.០០០រៀល បូករួម៧.០០០រៀល ។ ប្រាក់នេះបានកាត់យកពីប្រាក់៧.០០០រៀល ដែលដើមចោទបានបង់ទុករួច ហើយប្រាក់ស៊ើបអង្កេត៥.០០០រៀល ត្រូវបានចំណាយអស់ក្នុងពេលស៊ើបអង្កេត កាលបើហួសឧទ្ធរណ៍ត្រូវបង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ $\frac{១ \times ៣២៥.០០០៛}{១០០}$ = ៣.២៥០រៀល បន្ថែមទៀត ដែលត្រូវដាក់ចូលថវិការដ្ឋ៨០% និងបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ពន្ធសមាមាត្រត្រូវអោយដើមចោទបង់ទុកជាមុន ទើបបង្គាប់អោយចុងចម្លើយសងទៅដើមចោទវិញជាក្រោយ ។

៤-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តីសំរេចបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០១ របស់ឈ្មោះ លាវ សារីន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៦៩ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការខេត្តក្រចេះ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូលនៃសាលក្រម ។

-បានឃើញសាលដីកាវដ្ឋប្បវេណីលេខ៥៧ "ច" ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០១របស់ឈ្មោះលាវ សារីន ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៦៩ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការខេត្តក្រចេះ ចោលជាអសារបង់ ។

៣-ប្រគល់ដីទំនាស់ទំហំ២៦.៥០ម ×៣៦.២០ម ស្ថិតនៅភូមិឈើទាលភ្លោះក្រោម ឃុំកញ្ជរ ស្រុកឆ្លូង ខេត្តក្រចេះ អោយទៅដើមចោទឈ្មោះឈុយ សុភេច កាន់កាប់ជាកម្មសិទ្ធិតទៅ ។

៤-ប្រគល់ដីទំនាស់ទំហំ២៦.២០ម ×៦២.៨០ម ស្ថិតនៅភូមិឈើទាលភ្លោះក្រោម ឃុំកញ្ជរ ស្រុកឆ្លូង ខេត្តក្រចេះ អោយទៅឈ្មោះលាវ សារីន . លាវ វណ្ណី . លាវ ប៊ុនធីន . លាវ វណ្ណា និង ឈុយ រម្ធនី ដែលមានចុងចម្លើយឈ្មោះលាវ សារីន ជាតំណាងកាន់កាប់ជាកម្មសិទ្ធិតទៅ ។

៥-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ និងបង្គាប់អោយដើមចោទបង់ពន្ធសមាមាត្រ១% លើថ្លៃដីទំនាស់ ។

៦-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ ។ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ២៣៣ ចុះថ្ងៃទី២១-០៦-២០០២ របស់ឈ្មោះ ឈុយ សុភេច ប្តឹងមិនសុខចិត្តពីសាលដីកាវដ្ឋប្បវេណីលេខ៥៧ "ច" ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ គ្រប់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៥ របស់ឈ្មោះ ឈុយ សុភេច ។

-បានឃើញសារណាតប ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៦ របស់ឈ្មោះ លាវ សារីន ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖ សាលដីកាវដ្ឋប្បវេណីលេខ៥៧ "ច" ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ បានសំរេចត្រឹមត្រូវហើយដោយផ្អែកតាមមាត្រា ៧២ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ។ សូមក្រុមប្រឹក្សាជំនុំជំរះពិនិត្យ និងសំរេចតាមច្បាប់ ។

-បានស្តាប់ចម្លើយរបស់ឈ្មោះ ឈុយ សុភេច នៅពេលសវនាការថា ៖ ដីស្រែពីកន្លែងដែលមានទំហំ២៦.៥ម×៣៦.២ម ដែលស្ថិតនៅភូមិឈើទាលភ្លោះក្រោម ឃុំកញ្ជរ ស្រុកឆ្លូង ខេត្តក្រចេះ ខ្លួនបានកាន់កាប់ចាប់តាំងពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ២០០០ ។ ចំណែកឯឈ្មោះលាវ សារីន មិនដែលបានមកកាន់កាប់ និងគ្រប់គ្រងដីនេះទេ ។ ម្យ៉ាងទៀតនៅឆ្នាំ២០០០ ប្រពន្ធខ្ញុំបាទឈ្មោះហ៊ាន សាភិន បានស្លាប់

ក្រោយមកឈ្មោះលាវ សារិន បានមកដណ្តើមកាន់កាប់ដីទំនាស់ ដោយអះអាងថា ជាមរតករបស់ឪពុកដើម និងម្តាយរបស់ខ្លួនតាំងពីសង្គមចាស់ ទើបខ្លួនប្តឹងមកតុលាការខេត្តក្រចេះដើម្បីសុំសិទ្ធិគ្រប់គ្រងដីជាកម្មសិទ្ធិ ។ ខ្លួនសំណូមពរ សូមក្រុមប្រឹក្សាជំនុំជំរះពិចារណា និងសំរេចប្រគល់ដីទំនាស់ទាំងពីរកន្លែងខាងលើ មកឱ្យខ្លួនគ្រប់គ្រងធ្វើជាកម្មសិទ្ធិស្របច្បាប់ ។

-បានស្តាប់ចម្លើយរបស់ឈ្មោះ លាវ សារិន នៅពេលសវនាការថា : នៅឆ្នាំ១៩៧៩ ខ្លួននិងម្តាយខ្លួនមានដីស្រែមួយកន្លែងទំហំ២៨អា គឺជាដីទំនាស់សព្វថ្ងៃនេះ ។ ខ្លួនបានបង្កបង្កើនផលលើដីនេះរហូតមក ។ ឆ្នាំ១៩៩៧ ម្តាយខ្លួនបានធ្វើលិខិតប្រគល់ដីស្រែនេះ មកអោយបងប្អូនខ្លួនបួននាក់ ។ ក្រោយម្តាយខ្លួនបានស្លាប់ធ្វើឱ្យក្រុមគ្រួសារខ្លួនកើតក្តីទំនាស់ដី ដែលបង្កឡើងដោយឪពុកចុងខ្លួន ដោយគាត់បានយកដីស្រែរបស់បងប្អូនខ្លួនទាំងបួននាក់ទៅប្រគល់ឱ្យកូនប្រសាររបស់គាត់ទៅវិញ ហើយក៏បង្កើតឱ្យមានការថ្លឹងថ្លស់គ្នារហូតមកដល់សព្វថ្ងៃនេះ ។ ខ្លួនសូមសំណូមពរសុំសិទ្ធិគ្រប់គ្រងដីនេះ ខ្លួនមិនព្រមប្រគល់ដីនេះឱ្យទៅឈ្មោះឈុយ សុភោច ឡើយ ។ ខ្លួនសូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក សួស សាមឿន មេធាវីការពារឱ្យដើមចោទនៅពេលសវនាការថា : កូនក្តីខ្លួនបានកាន់កាប់ដីទំនាស់នេះពីរកន្លែងតាំងពីឆ្នាំ១៩៧៩មក ដោយគាត់បានបង្កបង្កើនផលលើដីនេះជាវៀងរហូតមក ។ ចំណែកភាគី លាវ សារិន មិនដែលបានមកកាន់កាប់ និងបង្កបង្កើនផលលើដីទំនាស់នេះទេ ។ ដីទំនាស់នេះប្រពន្ធរបស់កូនក្តីខ្លួន និងកូនក្តីខ្លួនទុកសំរាប់រស់នៅដល់ពេលគាត់ចាស់ ។ ក្រោយមកប្រពន្ធកូនក្តីខ្លួនបានស្លាប់ ទើបភាគី លាវ សារិន បានមកប្តឹងកាន់កាប់ ។ ខ្លួនសូមបដិសេធសាលដីកាសាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល និងសំរេចប្រគល់ដីពីរកន្លែងនេះអោយកូនក្តីខ្លួនគ្រប់គ្រង និងធ្វើជាម្ចាស់ស្របច្បាប់ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីដើមចោទ .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៣៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ របស់លោកឈុយ សុភោច ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការរៀបចំ និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ដីពីរកន្លែងដែលមាននៅក្នុងកំណត់ហេតុវាស់វែង និងវាយតម្លៃដីវិវាទ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០០ គឺជាទ្រព្យរួមរបស់លោកឈុយ សុភោច និងអ្នកស្រីហ៊ាន សាភិន ។

-យល់ឃើញថា លាវ សារិន តំណាងឱ្យសន្តតិជនដែលជាចុងចម្លើយមានសិទ្ធិទទួលបេតិកភ័ណ្ឌរបស់អ្នកស្រី ហ៊ាន សាភិន ដែលបានទទួលមរណៈភាពទៅហើយនោះ តាមគោលការណ៍សន្តតិកម្ម ។

-យល់ឃើញថា ការដែលលោកមេធាវីចុងចម្លើយលើកឡើងថា មុនមរណៈភាពអ្នកស្រី ហ៊ានសាភិន បានធ្វើការបែងចែកដីរួចហើយនោះ តុលាការកំពូលពុំអាចពិចារណាបានឡើយ ពីព្រោះលិខិត

បណ្តឹងនោះ ធ្វើឡើងដោយអ្នកស្រី ហ៊ាន សាភិន តែម្នាក់ឯងគត់ ពុំមានការចូលរួមពីលោកឈុយ សុភេច ទេ ដែលជាអង្គហេតុមួយផ្សេង ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៥៧ "ច" ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

## ហេតុដូច្នេះ

## *វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី :*

១-ទទួលបណ្តឹងសាទុក្ខលេខ២៣៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ របស់លោកឈុយ សុភេច ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៥៧ "ច" ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ របស់សាលា-ឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលចុងចម្លើយបានបង់ គឺ:

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

-តម្រូវឱ្យដើមចោទសងប្រាក់ចំនួន១៩.០០០រៀល ទៅចុងចម្លើយវិញ ។

បង្គាប់ឱ្យដើមចោទ បង់ពន្ធសមាមាត្រតាមការកំណត់របស់សាលាឧទ្ធរណ៍ ។

៤-សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ។ /\